**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:**០០៨/០៨ កហ អ.គ.គ

# កំណត់ហេតុ
# ស្តីពី
# កម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល សិក្ខាសាលានៅសណ្ឋាគារសាន់វ៉េ

ឆ្នាំពីរពាន់ប្រាំបី ខែ មីនា ថ្ងៃទី ម្ភៃប្រាំមួយ វេលាម៉ោងប្រាំបី នៅសណ្ឋាគារសាន់វ៉េ មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពរបស់ឯកឧត្តម **សំ សុខផល** ជាប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្សព្វផ្សាយកម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល ដោយមានការចូលរួមពីសំណាក់ឯកឧត្តម **ចាំ សុជាតិវង្ស** អភិបាលរងរាជធានីភ្នំពេញ និងឯកឧត្តមអភិបាលរងខេត្តកណ្តាល ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ចាំ សុជាតិវង្ស** អភិបាលរងរាជធានីភ្នំពេញ បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈអធិបតី គណៈប្រតិភូនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឯកឧត្តមអភិបាលខេត្តរងខេត្តកណ្តាល ឯកឧត្តមប្រធានតុលាការក្រុងភ្នំពេញ និងឯកឧត្តមប្រធានតុលាការគំរូខេត្តកណ្តាល និងភ្ញៀវកិត្តិយសដែលមានវត្តមានក្នុងអង្គសិក្ខាសាលានាថ្ងៃនោះ ព្រមទាំងថ្លែងអំណរគុណដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ឯកឧត្តមបានបញ្ជាក់ថា អង្គសិក្ខាសាលានាពេលព្រឹកនេះ គឺត្រូវបានរៀបចំឡើង ដើម្បីផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ និងចែករំលែកបទពិសោធន៍ផ្សេងៗនៃការកែទម្រង់ច្បាប់ និងតុលាការ ជូនមន្ត្រីស្ថាប័ន មន្ទីរជំនាញផ្សេងៗនៅតាមបណ្តាខេត្តក្រុងអោយមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត ។ ឯកឧត្តមអភិបាលរងរាជធានី

ភ្នំពេញ ក៏ដូចឯកឧត្តមអភិបាលរងខេត្តកណ្តាលដែរ សុទ្ធតែមានសង្ឃឹមថា សកម្មភាពកំណែទម្រង់របស់ខេត្តកណ្តាល និងរាជធានីភ្នំពេញនឹងអាចដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាលបានទាំងស្រុង ។

បន្ទាប់ពីសន្ទរកថារបស់ឯកឧត្តមអភិបាលរងរាជធានីភ្នំពេញបានបញ្ចប់ ឯកឧត្តមក៏បានប្រកាសបើកអង្គសិក្ខាសាលាក្នុងពេលនោះតែម្តង ។

ឯកឧត្តម **សំ សុខផល** បានធ្វើបទអន្តរាគមន៍ ជម្រាបជូនអង្គសិក្ខាសាលាអំពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទីបីនៃរដ្ឋសភា ដែលមានកំណែទម្រង់បួនជាស្នូលមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងទ័ព កំណែទម្រង់ច្បាប់ និងតុលាការ និងការប្រឆាំងអំពើពុករលួយ ក្នុងគោលដៅរួមមួយ គឺអភិបាលកិច្ចល្អ ។

ឯកឧត្តមបានជម្រាបជូនអង្គសិក្ខាសាលាទាំងមូលអំពីដំណើរការនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលឯកឧត្តមបានលើកឡើងពីរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ក.ក.ច.ន.យ) ដែលបានបង្កើតឡើង នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម **ឌិត មុន្ទី** ប្រធានតុលាការកំពូលជាសហប្រធាន ។ បន្ទាប់មក ឯកឧត្តមបានជម្រាបជូនអង្គប្រជុំអំពីអង្គភាពនៅក្រោមឱវាទរបស់ក្រុមប្រឹក្សា :

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍(អ.ស.ស)ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ។
- អង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ)ដែលបានបង្កើតឡើងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ ។
- ក្រុមការងារបច្ចេកទេសចម្រុះនៅខែមីនា ឆ្នាំ ២០០៥ ដើម្បីជួយសម្របសម្រួលការងារជាមួយដៃគូអភិវឌ្ឍន៍ ។

នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវឯកសារ ស្តីពីសកម្មវិធីសកម្មភាពអនុវត្តជាយុទ្ធសាស្ត្រ ។

កម្មវិធីសកម្មភាពនេះចែកចេញជាបីផ្នែក :

- សកម្មភាពរយៈពេលខ្លី គឺ ២០០៥-២០០៧ (២០០៤-២០០៦)
- សកម្មភាពរយៈពេលមធ្យម និង គឺ ២០០៧-២០០៩ (២០០៦-២០០៨)
- សកម្មភាពរយៈពេលវែង គឺ ចាប់ពីឆ្នាំ ២០០៩ ឡើងទៅ ។

បន្ទាប់ពីបទអន្តរាគមន៍របស់ឯកឧត្តមប្រធានមក ឯកឧត្តមបានអញ្ជើញឯកឧត្តម **ជីវ កេង** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាអ្នកមានបទពិសោធន៍ខាងតុលាការ ដើម្បីបង្ហាញពីការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់របស់តុលាការក្រុងភ្នំពេញ ។

ឯកឧត្តម **ជីវ កេង** បានលើកឡើងនូវបញ្ហាប្រឈមមុខជាច្រើន ដែលត្រូវដោះស្រាយ គឺ:

- មានភាពមិនប្រក្រតី-ការប្រព្រឹត្តទៅមិនសមរម្យរបស់មន្ត្រីតុលាការ តែធ្វើអោយជះឥទ្ធិពលដល់មជ្ឈដ្ឋានខាងក្រៅ ហើយដែលមានបញ្ហាថ្នាំងថ្នាក់ដល់ប្រព័ន្ធយុត្តិធម៌
- បញ្ហាដែលតុលាការភ្នំពេញបានអនុវត្តគួរអោយកត់សំគាល់ចាប់តាំងពីឆ្នាំ២០០៥ ពេលដែលឯកឧត្តមចូលមកកាន់តំណែងតុលាការក្រុងភ្នំពេញមាន :

    ១- ការអនុវត្តក្រមសីលធម៌របស់ចៅក្រម ដែលឯកឧត្តមបានលើកឡើងថា បញ្ហាក្រមសីលធម៌ចៅក្រម ជាបញ្ហាសំខាន់ណាស់ ចំពោះចៅក្រម និងព្រះរាជអាជ្ញា ។

    ២- ការបណ្តុះបណ្តាលបន្ត : ចៅក្រម ព្រះរាជអាជ្ញាទាំងអស់ត្រូវបានបណ្តុះបណ្តាលបន្តនៅសាលាភូមិន្ទចៅក្រមស្របតាមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ។ ចំណែកក្រឡាបញ្ជីនៅតុលាការភ្នំពេញ ក៏ត្រូវបានធ្វើការបណ្តុះបណ្តាលបច្ចេកទេសជំនាញរយៈពេល៣ខែ ហើយបញ្ចប់ពីរយៈពេលនេះក្រឡាបញ្ជីត្រូវធ្វើការប្រឡង បើសិនជាក្រឡាបញ្ជីណាប្រឡងជាប់នោះអាចបានចូលក្នុងក្របខណ្ឌក្រឡាបញ្ជី ។

    ៣- ការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី : នៅទីក្រុងភ្នំពេញនេះក្រមក្រមនីតិវិធីរដ្ឋប្បវេណីបានចូលជាធរមានមុនគេ ហើយឯកឧត្តមបានជម្រាបថា នេះជាមោទនភាពរបស់តុលាការក្រុងភ្នំពេញមានលទ្ធភាព ហើយបានអនុវត្តដោយជោគជ័យនូវក្រមនេះនៅតាមបណ្តាខេត្តនានាទាំងអស់ ដោយ ឡែកតុលាការក្រុងភ្នំពេញបានអនុវត្តក្រមនេះយ៉ាងរលូនចាប់តាំងពីខែ កក្កដា ឆ្នាំ ២០០៧មកម្ល៉េះ ។

    ៤- លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តុលាការក្រុងភ្នំពេញបានអនុវត្តនូវក្រមនីតិវិធីព្រហ្មទណ្ឌបានចូលជាធរមានតាំងពី ខែ កញ្ញា ឆ្នាំ ២០០៧ ដោយមានការឧបត្ថម្ភពីសាលាក្រុងក្នុងការបោះពុម្ពដោយមានដំណើរការល្អប្រសើរហើយ ប៉ុន្តែក៏នៅមានចំណុចខ្វះខាតខ្លះដែរ ។

ចំណែកការអនុវត្តយុទ្ធសាស្ត្រធំៗដែលសមត្ថកិច្ចរបស់ខ្លួន យើងបានធ្វើដោយជោគជ័យគឺ :

១- អំពើភេវរកម្ម : យើងបានសហការយ៉ាងម៉ត់ចត់ជាមួយកងកម្លាំងនគរបាល ពិសេសនគរបាលក្រុងភ្នំពេញប្រកបដោយប្រសិទ្ធិភាព ។ ឯកឧត្តមបានលើកឡើងថា ចាប់តាំងពីឆ្នាំ ២០០៥ រហូតមកដល់ពេលនេះ មិនមានការចាប់ជំរិត ឬក៏ការបង្ករភេវរកម្មណាមួយឡើយ

២- អំពើជួញដូរផ្លូវភេទលើកុមារ និងស្ត្រី : ខាងតុលាការក្រុងបានធ្វើការផ្តន្ទាទោសយ៉ាងសុក្រិត្យទៅតាមផ្លូវច្បាប់ ទោះបីជាមានអន្តរាគមន៍ពីខាងភាគីណាក៏ដោយ

៣- បញ្ហាគ្រឿងញៀន ក៏មានការអនុវត្តចំពោះជនល្មើសផងដែរ

៤- ចំពោះបទល្មើសឆក់ប្លន់ ខាងតុលាការក្រុងភ្នំពេញបានធ្វើទៅតាមច្បាប់រួចរាល់ហើយដែរ

៥- បញ្ហាបទល្មើព្រៃឈើ រាជរដ្ឋាភិបាលយើងបានអនុញ្ញាតិអោយតុលាការក្រុងភ្នំពេញចាត់វិធានការរួចរាល់ហើយដែរ មិនថាកើតនៅក្នុងខេត្តណា ឬតំបន់ណានោះទេ គឺត្រូវតែបញ្ជូនមកតុលាការក្រុងភ្នំពេញដែរ

៦- បញ្ហាអំពើហឹង្សាក្នុងគ្រួសារ តុលាការយើងបានយកចិត្តទុកដាក់ និងមានការគាំទ្រយ៉ាងពេញទំហឹងក្នុងការដោះស្រាយ និងទប់ស្កាត់ក្នុងរឿងនេះ

៧- បញ្ហាផ្លាស់ប្តូរតុលាការ ១ភាគបួន ដែលត្រូវផ្លាស់ប្តូររៀងរាល់៤ឆ្នាំម្តង ដើម្បីកុំអោយមានការចាក់ឬសដែលជាហេតុបង្ករអោយមានភាពពុករលួយ

៨- បញ្ហាសហការជាមួយអាជ្ញាធរដែនដី មូលដ្ឋាន នគរបាល កងរាជអាវុធហត្ថ ខេត្ត-ក្រុងមានការសហការគ្នាបានល្អ ។ ចំណែកបណ្តាញសារព័ត៌មានក៏មិនសូវមានការលើកឡើងទេចំពោះបញ្ហាតុលាការនេះ ហើយក៏មានការទទួលស្គាល់ពីបណ្តាសង្គមស៊ីវិល ចំពោះវិស័យច្បាប់ និងតុលាការ នេះ ។

ឯកឧត្តមបានលើកឡើងផងដែរពីបញ្ហាប្រឈមមុខមួយចំនួន គឺ :

- បញ្ហាខ្វះចៅក្រម : បច្ចុប្បន្ននេះចៅក្រមមានចំនួន១៤ នាក់ ចំណែកព្រះរាជអាជ្ញាមានចំនួន៧នាក់
- រីឯក្រឡាបញ្ជីតាមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល មានធ្វើការបណ្តុះបណ្តាលបន្តនៅសាលាភូមិន្ទចៅក្រម ។ ហើយចំពោះប្រាក់ខែក្រឡាបញ្ជីមានតិចតួចជាហេតុធ្វើអោយមានការលំបាកដល់ជីវភាពរបស់គាត់ ដូច្នេះញុាំងអោយរាំងស្ទះដល់ដំណើរការតុលាការផងដែរ ។

ឯកឧត្តម **ខៀវ សារ៉េត** ប្រធានតុលាការខេត្តកណ្តាលបានលើកបង្ហាញពីលទ្ធផលជាក់ស្តែងក្នុងខេត្តកណ្តាល ។ ឯកឧត្តមបានលើកឡើងថា បើសិនជាយើងពិនិត្យទៅលើទិដ្ឋភាពរបស់តុលាការយើងសព្វថ្ងៃ ថាតើមានភាពខ្លាំង ឬខ្សោយ? ហើយបើតុលាការយើងមានភាពខ្លាំង តើហេតុអ្វីយើងចាំបាច់ត្រូវធ្វើការកែទម្រង់ ? ក្នុងពេលនោះដែរ ឯកឧត្តមបានរំលឹកឡើងពីតុលាការក្រោយពីឆ្នាំ ១៩៧៩ ថា កាលនោះយើងគ្មានតុលាការទេ គឺមានត្រឹមតែអ្នកមានវិជ្ជាជីវៈតុលាការប្រហែលជាចំនួន៧ ទៅ៨ នាក់តែប៉ុណ្ណោះ ។ ដូច្នេះនៅពេលនោះតុលាការនៅមានលក្ខណៈខ្សោយ ដោយខ្វះខាតធនធានមនុស្សនេះ ។ ផ្អែកតាមយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ រដ្ឋាភិបាលបានបង្កើតសាលាភូមិន្ទនៅក្រោមដើម្បីធ្វើការបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញារហូតមកដល់ពេលនេះបណ្តុះបណ្តាលបានចំនួន៦វគ្គហើយ

ថ្មីៗនេះរដ្ឋាភិបាលបានសាងសង់តុលាការនៅតាមខេត្តក្រុងចំនួន០៤ហើយផងដែរ ។ ឯកឧត្តមបានជម្រាបទៀតថា បញ្ហាអាគារ និងសម្ភារៈមានលក្ខណៈគ្រប់គ្រាន់ហើយ ។ ចំពោះបញ្ហាកិច្ចការរដ្ឋបាលតុលាការមានការប្រែប្រួល និងអភិវឌ្ឍន៍យ៉ាងខ្លាំងដោយផ្អែកទៅលើការបណ្តុះបណ្តាលដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីជាដើម សុទ្ធសឹងតែជាអ្នកមានសមត្ថភាព និងផ្អែកទៅលើច្បាប់ក្រមថ្មីដែលត្រូវបានអនុម័តរួច ។ ជាចុងក្រោយឯកឧត្តមបានលើកឡើងពីការកែលំអពន្ធនាគារអោយស្របតាមស្តង់ដារអន្តរជាតិដោយមាន ការជួយឧបត្ថម្ភពីប្រទេសជាដៃគូអភិវឌ្ឍន៍នានា ។

ឯកឧត្តម **សួន លាងហៃ** បានធ្វើការបង្ហាញជូនអង្គសិក្ខាសាលាអំពីដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានបង្កើតឡើង នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម **ឌិត មន្ទី** ប្រធានតុលាការកំពូល ជាសហប្រធាន ។ ឯកឧត្តមបានបង្ហាញជូនអង្គប្រជុំអំពីអង្គភាពផ្សេងៗរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលរួមមាន អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ និងអង្គភាពគ្រប់គ្រងគម្រោង ( PMU ) ដែលបានបង្កើតឡើងនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ឯកឧត្តមបានបញ្ជាក់ជូនថា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានបេសកកម្មផ្តួចផ្តើមជំរុញ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តន៍កម្មវិធីនយោបាយ និងកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ ស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលមានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រធាន ។

យើងមានចក្ខុវិស័យ មានគោលដៅ មានទិសដៅជាយុទ្ធសាស្ត្រទាំង៧ ហើយទីបញ្ចប់ គឺមានកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងនោះទៀត ដែលត្រូវបានបែងចែកទៅជារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

នៅក្នុងកម្មវិធីសំណួរ-ចម្លើយ ទាក់ទងទៅនឹងកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ

លោក **សុខ រឿន** ព្រះរាជអាជ្ញារង ក្រុងភ្នំពេញ មានការចាប់អារម្មណ៍គួរបញ្ចូលពាក្យមន្ត្រីជាមួយភ្នាក់ងារអនុវត្ត ទើបមានលក្ខណៈពេញលេញ ។

ឯកឧត្តម **ចាំ សុជាតិវង្ស** អភិបាលរងក្រុងភ្នំពេញ បានមានប្រសាសន៍កោតសរសើរចំពោះការរៀបចំរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានរៀបចំឡើងស្របទៅតាមកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ហើយឯកឧត្តមបានធ្វើសំណូមពរដូចខាងក្រោមនេះ :

១- សូមអោយមានការរៀបចំជាផ្លូវការ បើសិនជាអាចធ្វើទៅបាននូវយន្តការដោះស្រាយវិវាទក្រៅតុលាការ ចំពោះបញ្ហាតូចតាច ពីព្រោះវាជាការជួយរំលែកបន្ទុកតុលាការ ។ ឯកឧត្តមបានលើកឡើងថា បើសិនជា

ដីធ្លីមិនទាន់មានកម្មសិទ្ធិស្របច្បាប់យើងត្រូវដោះស្រាយតាមរយៈសូរិយោដី បើសិនជាមានកម្មសិទ្ធិរួច ហើយនោះ យើងត្រូវដោះស្រាយតាមតុលាការ ដូច្នេះឯកឧត្តមស្នើសុំអោយមានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមាននៅអាជ្ញាធរមូលដ្ឋាន ថ្នាក់ឃុំ ។

២- សំណូមពរអោយជ្រើសរើសសិស្សចៅក្រមបន្ថែមទៀត ដើម្បីកុំអោយមានការកកស្ទះសំណុំរឿង ព្រោះថាក្នុងមួយឆ្នាំរើសត្រឹមតែ៥៥នាក់នោះ មិនគ្រប់គ្រាន់ទេ គួរតែជំរុញផ្នែកធនធានមនុស្សនេះអោយបានច្រើនតាមដែលអាចធ្វើទៅបាន ។

៣- ឯកឧត្តមសំណូមពរអោយមានឯកទេសផ្សេងៗនៅក្នុងតុលាការតែមួយ ដូចជាឯកទេសខាងពាណិជ្ជកម្ម ឯកទេសរដ្ឋបាល និងព្រហ្មទណ្ឌ ជាដើម ។ល។

៤- ឯកឧត្តមបានលើកឡើងថា ការផ្សព្វផ្សាយនៅមិនទាន់ស៊ីជម្រៅនៅឡើយទេ ដូច្នេះគួរតែមានផែនការ និងបណ្តាញច្បាស់លាស់ ឬសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអោយមានលក្ខណៈទូលំទូលាយ ដើម្បីអោយបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋ ។

វាគ្មិនបានមានប្រសាសន៍ថា តុលាការខេត្តនានាមានការផ្លាស់ប្តូរហើយ នៅឡើយតែប្រធាន តុលាការខេត្តកោះកុង ឈ្មោះ **កែវ ស៊ីម** នេះ មិនទាន់ផ្លាស់ប្តូរ ហេតុនេះឯកឧត្តមបានស្នើសុំអោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ជួយអន្តរាគមន៍ក្នុងរឿងនេះផង ។

ឯកឧត្តម **ជីវ កេង** បានមានប្រសាសន៍ថា មានអនុក្រិត្យផ្លាស់ប្រធានតុលាការខេត្តកោះកុងនេះរួចហើយថាត្រូវផ្លាស់ទៅកាន់ខេត្តព្រះវិហារ គ្រាន់តែពុំទាន់បានប្រារព្ធពិធីផ្លាស់ប្តូរតំណែងប៉ុណ្ណោះ។

ទាក់ទងទៅនឹងកង្វះខាតធនធានមនុស្សដែលឯកឧត្តមអភិបាលខេត្តរងក្រុងបានលើកឡើងនោះ ពិតជាត្រឹមត្រូវដែលស្នើសុំអោយជ្រើសរើសចៅក្រមអោយបានច្រើននោះ ឯកឧត្តមបានលើកយករឿងនេះទៅជម្រាបជូនក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាក៏យល់ព្រមក្នុងសំណើនេះដែរ ក៏ប៉ុន្តែនៅមានបញ្ហាទាក់ទិននឹងថ្នាក់រៀន ព្រោះនៅសាលាភូមិន្ទចៅក្រមបន្ទប់រៀនមិនអាចទទួលសិស្សបានច្រើននោះទេ និងបញ្ហាខ្វះគ្រូបង្រៀនផងដែរ ។ ទាក់ទងនឹងទំនើបនីយកម្មចៅក្រមនេះ ឯកឧត្តមលើកឡើងថា នៅស្រុកគេមានជំនាញដាច់ដោយឡែកៗពីគ្នា មានផ្នែកពាណិជ្ជកម្ម រដ្ឋបាល និងស៊ីវិល ។ល។ ប៉ុន្តែចំពោះស្រុកយើងដោយសារតែខ្វះធនធានមនុស្ស ដូច្នេះតុលាការយើងកាន់ព្រហ្មទណ្ឌផង ស៊ីវិលផង ។ ចំពោះការផ្សព្វផ្សាយច្បាប់ ឯកឧត្តមយល់ស្របទៅនឹងសំណើរបស់ឯកឧត្តមអភិបាលរងក្រុងភ្នំពេញផងដែរ ។

ឆ្លើយតបនឹងសំណួរថា តើចាត់វិធានការបែបណាដើម្បីអោយតុលាការខេត្តកណ្តាលទៅជាតុលាការគំរូ ? ឯកឧត្តម **ខៀវ សារ៉េត** មានប្រសាសន៍ថា លោកមានលក្ខន្តិ ៦ យ៉ាង គឺ : អាគារអោយបានសមរម្យ-សម្ភារៈឱ្យបានគ្រប់គ្រាន់-ធនធានមនុស្ស-ច្បាប់ជាគោលធំៗ-កិច្ចការរដ្ឋបាលតុលាការ ( ត្រួតពិនិត្យសំណុំរឿង ) និងឯករាជ្យភាពរបស់តុលាការ ។ ប៉ុន្តែលោករង់ចាំស្តង់ដារទាំង១១ដែលក្រុមការងារតុលការគំរូកំពុងតែរៀបចំ ។

សំណួរមួយទៀតសួរថា ហេតុអ្វីបានជាបទល្មើសព្រៃឈើ មិនចាត់វិធានការនៅកន្លែងដែលកំពុងមានសកម្មភាពនៅតាមខេត្តនីមួយៗនោះតែម្តង ? ឯកឧត្តម **ជីវ កេង** បានបញ្ជាក់ថា ប្រសិនជាបទល្មើសនោះ ឋិតនៅក្នុងលក្ខណៈតូចតាច យើងអាចធ្វើនៅកន្លែងប្រព្រឹត្តបទល្មើសនោះតែម្តង ប៉ុន្តែបើបទល្មើសព្រៃឈើនោះមានលក្ខណៈធំៗ យើងត្រូវបញ្ជូនមក តុលាការក្រុងភ្នំពេញ ។

លោក ជំទាវ **សម មុនីកា** អគ្គនាយករងក្រសួងកិច្ចការនារី បានជម្រាបជូនអង្គសិក្ខាសាលាអំពីសកម្មភាពការងារមួយចំនួនដែលខាងលោកជំទាវបានធ្វើ និងផ្សព្វផ្សាយនូវច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីការជួញដូរផ្លូវភេទ ជាដើម នៅតាមបណ្តាខេត្តក្រុង ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានធ្វើបទបង្ហាញអំពីគំនូសតារាងស្តីពីភាពជឿនលឿនជាភាគរយនៃការអនុវត្តកម្មវិធីសកម្មភាពយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការកម្ពុជាទៅតាមទិសដៅជាយុទ្ធសាស្ត្រទាំង៧ ។

១- ទិសដៅជាយុទ្ធសាស្ត្រទី១ : **ស្តីពីការការពារសិទ្ធិសេរីភាពរបស់បុគ្គល** ចំណុចសំខាន់គឺការបង្កើនការយល់ដឹងអំពីសិទ្ធិមូលដ្ឋាន និងពលរដ្ឋវិជ្ជា។ ឯកឧត្តមបានជម្រាបអំពីភាគរយនៃទិសដៅជាយុទ្ធសាស្ត្រទី១ថា មានចំនួន១៩ សកម្មភាព ក្នុងនោះមានសកម្មភាពរយៈពេលខ្លី ចំនួន ៥ សកម្មភាព ចំណែករយៈពេលមធ្យមមាន ចំនួន៦ សកម្មភាព និងសកម្មភាពរយៈពេលវែងមាន ចំនួន ៨ សកម្មភាព ។

២- ទិសដៅជាយុទ្ធសាស្ត្រទី២ : **ស្តីពីធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់** ឯកឧត្តមមានប្រសាសន៍ថា យើងបានអនុម័តច្បាប់ចំនួន ១១៨ច្បាប់ នៅក្នុងអាណត្តិទី៣នៃរដ្ឋសភានេះ ។

៣- ទិសដៅជាយុទ្ធសាស្ត្រទី៣ស្តីពីការ**ផ្តល់លទ្ធភាពអោយទទួលបានព័ត៌មានច្បាប់ និងតុលាការអោយកាន់តែប្រសើរឡើង** បច្ចុប្បន្ននេះយើងកំពុងតែសហការជាមួយបារាំង និងUNDP សហការគ្នាធ្វើយ៉ាងណាអោយច្បាប់នានាបានទៅដល់ប្រជាពលរដ្ឋដោយមាននាយកដ្ឋានរាជកិច្ច ជាអ្នកកំពុងធ្វើកិច្ចការនេះ ។

៤- ទិសដៅជាយុទ្ធសាស្ត្រទី៤ស្តីពីការ**ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃរឿងក្តី និងសេវាពាក់ព័ន្ធ** ។

៥- ទិសដៅជាយុទ្ធសាស្ត្រទី៥ : **ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាអយ្យការ**

៦- ទិសដៅជាយុទ្ធសាស្ត្រទី៦ : **បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ទាក់ទងនឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ សហការជាមួយ UNDP បានសិក្សារៀបចំយន្តការដោះស្រាយវិវាទនៅតាមស្រុក ឃុំ នៃខេត្តមួយចំនួន ។

៧- ទិសដៅជាយុទ្ធសាស្ត្រទីក៧ស្តីពីការ**ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការដើម្បីបំពេញអាណត្តិខ្លួនបានសម្រេច** ។

កញ្ញា **សេង ម៉ាលី** មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ បានសន្និដ្ឋានថាប្រជាពលរដ្ឋអស់ជំនឿទៅលើស្ថាប័នអ្នកអនុវត្តច្បាប់ ជាពិសេសពាក់ព័ន្ធនឹងដីធ្លីជាដើម និងមួយទៀតគឺការដាក់គំនាបរបស់ស្ថាប័នអ្នកអនុវត្តច្បាប់ដើម្បីយកលុយពីប្រជាពលរដ្ឋ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានមានប្រសាសន៍ថា យើងមិនអាចវិនិច្ឆ័យទៅលើការអះអាងរបស់គូភាគីតែម្ខាងទេ ហើយឯកឧត្តមបានមាន ប្រសាសន៍ទៀតថា ការធ្វើសិក្ខាសាលានាថ្ងៃនេះ គឺចង់បានការផ្តល់ជាមិតយោបល់ ថាតើមូលហេតុអ្វីបានជាពួកគាត់អស់ជំនឿលើស្ថាប័នអ្នកអនុវត្តច្បាប់ ? ។

លោក **លី តៃសេង** ជាអគ្គលេខាធិការគណៈមេធាវី បានជម្រាបជូនអង្គសិក្ខាសាលាអំពីការចូលរួមចំណែកយ៉ាងសកម្មរបស់គណៈមេធាវីជាមួយនឹងកំណែទម្រង់ច្បាប់ និងតុលាការនេះ ដូចជាការពង្រីកសកម្មភាពការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ ដោយសហការជាមួយមេធាវីអង្គការគ្មានព្រំដែន ដែលមានការិយាល័យនៅគ្រប់ខេត្ត ក្រុង ។ លោកបានជម្រាបផងដែរថា សព្វថ្ងៃនេះមេធាវីមានចំនួន ៤៣៦នាក់ ដើម្បីបំពេញការងារជារបៀបបង្វិល ដោយមានថវិកាឧបត្ថម្ភពីខាងរាជរដ្ឋាភិបាល ហើយកិច្ចការនេះខាងគណៈមេធាវីបានសម្រួលការទាក់ទងកិច្ចសហការ ជាមួយនឹងមន្ត្រីប៉ូលិស និងមន្ត្រីតុលាការជាដើម ។

លោកក៏បានស្នើសុំអោយមានការជួបគ្នាជាញឹកញាប់រវាងមន្ត្រីពាក់ព័ន្ធក្នុងការអនុម័ត និងកិច្ចសហការគ្នា ដើម្បីផលប្រយោជន៍រួម និងដើម្បីអោយការងាររលូនទៅមុខ ។

លោក **ឈិត ឈួនយ៉ាត** មន្ត្រីផ្នែកសិទ្ធិមនុស្សខ្មែរក្រោម លោកបានស្នើសុំអោយសមាជិកឧត្តមក្រុមប្រឹក្សាអង្គចៅក្រមលាលែងពីតួនាទីក្នុងតុលាការ ។ ពាក់ព័ន្ធនីតិវិធីនៃការឃុំខ្លួនជនជាប់ចោទ ដែលការឃុំខ្លួនត្រូវបានអូសបន្លាយមុននឹងសវនាការ លោកសួរថា តើបញ្ហានេះអាចប៉ះពាល់ដល់សិទ្ធិជនជាប់ចោទដែរឬទេ ?

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានឆ្លើយបំភ្លឺថា សំណូមពរដែលលោកបានលើកឡើងខាងលើនេះ ឯកឧត្តមនឹងលើកយកសំណើនេះជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ហើយចំពោះការឃុំខ្លួនជនជាប់ចោទនោះអាចមើលបញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

លោកស្រី **ពេជ្រ សារុំ** ប្រធានកិច្ចការនារី រាជធានីភ្នំពេញ បានសំណូមពរអោយមានក្រុមផ្សព្វផ្សាយអំពីច្បាប់ដើម្បីអោយបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋ ។ លោកស្រីមានប្រសាសន៍បន្ថែមទៀតថា យើងគួរជ្រើសរើសក្រុមការងារណាដែលនៅជិតដិតនឹងប្រជាពលរដ្ឋ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានឯកភាពចំពោះមតិរបស់លោកស្រី **ពេជ្រ សារុំ** ហើយឯកឧត្តមក៏បានជម្រាបផងដែរថា យើងបានធ្វើការផ្សព្វផ្សាយការងារយើងតាំងពី ឆ្នាំ ២០០៦មកម្ល៉េះ ។

លោក ជំទាវ **សម មុនីភា** បានស្នើសុំអោយធ្វើការផ្សព្វផ្សាយច្បាប់អោយបានដល់ប្រជាពលរដ្ឋតាមរបៀបជា Street Law នៅតាមបណ្តាភូមិឃុំ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានមានប្រសាសន៍ថា បច្ចុប្បន្ននេះមានអង្គការមួយកំពុងតែរៀបចំសៀវភៅ Street Law ។ ហើយតាមរយៈ Street Law នេះ ឯកឧត្តមបានបញ្ជាក់ថា មិនមានមាត្រាទេ គឺលើកយកបញ្ហាច្បាប់ជាក់ស្តែងមកផ្សព្វផ្សាយតែម្តង ។

ដើម្បីសរុប ឯកឧត្តម **សំ សុខផល** បានយល់ស្របចំពោះការធ្វើការផ្សព្វផ្សាយនៅតាមបណ្តាខេត្ត ព្រោះថានេះជាទិសដៅមួយយ៉ាងសំខាន់ ហើយឯកឧត្តមប្រធានបានអះអាងថា នឹងព្យាយាមពន្យល់ដៃគូអភិវឌ្ឍន៍ ឬប្រទេសផ្តល់ជំនួយ ដើម្បីអោយគេយល់ និងព្រមជួយយើងក្នុងការផ្សព្វផ្សាយនេះ ដើម្បីចៀសវាងគេនិយាយថា យើងមិនមានផែនការច្បាស់លាស់ ។ ឯកឧត្តមបានមានប្រសាសន៍ទៀតថា ការធ្វើអង្គសិក្ខាសាលានាថ្ងៃ បានផ្តល់នូវចំណុចសំខាន់ៗយ៉ាងច្រើន ហើយឯកឧត្តមសង្ឃឹមថា ឯកឧត្តម លោកជំទាវអស់លោក លោកស្រីទាំងឡាយ នឹងបន្តកិច្ចសហប្រត្តិបត្តិការជាបន្តទៀត ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០៨*

**បានឃើញ និងឯកភាព**

**នាយកអ.គ.គ** | **អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** | **សេង វ៉ាន់ដា** | **ស៊ុន សិរីវុធ**